# ព្រះរាជក្រឹត្យ

នស/រកត/០៣០៣/ ១១៥

## ស្តីពី

## ការកំណត់របេណីយដ្ឋានប្រាសាទព្រះវិហារ

*****

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៣

## ត្រាស់បង្គាប់

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

កំណត់រមណីយដ្ឋានវប្បធម៌នៃប្រាសាទព្រះវិហារ ជារមណីយដ្ឋានការពារ ស្ថិតនៅលើភ្នំព្រះវិហារនៃជួរភ្នំដងរែក ក្នុងភូមិសាឯម (អតីតភូមិស្វាយជ្រុំ) ឃុំកន្ទួត ស្រុកជាំក្សាន្ត ក្នុងខេត្តព្រះវិហារ ។

**មាត្រា ២.-**

ការបង្កើតរមណីយដ្ឋានការពារនេះមានគោលបំណង :

- អភិរក្សកេរដំណែលវប្បធម៌ ទាំងខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា និង លើកកំរិតតំលៃរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត
- អភិរក្ស ទេសភាពវប្បធម៌ និង អភិវឌ្ឍតំបន់ទេសចរណ៍
- ការពារបរិស្ថាន ធម្មជាតិក្នុងតំបន់ តាមភូមិសាស្ត្រជាក់ស្តែង

### ជំពូកទី ២
### ការកំណត់តំបន់

**មាត្រា ៣.-**

ត្រូវឱ្យត្រួតពិនិត្យរាល់ការអភិវឌ្ឍរមណីយដ្ឋានការពារ ដោយគោរពតាមប្លង់កំណត់តំបន់ និង ការចាត់ចែងគ្រប់គ្រងតំបន់ តាមចំណាត់ថ្នាក់តំបន់ត្រូវការពារ ។

**មាត្រា ៤.-**

រមណីយដ្ឋានការពារប្រាសាទព្រះវិហារ ត្រូវចាត់ជា ៣ (បី) តំបន់ផ្សេងៗគ្នា ហើយត្រូវទទួលកំរិតការពារខុសៗគ្នា :

ក - តំបន់ទី ១ : ជាតំបន់រមណីយដ្ឋានប្រាសាទ ហៅថា **តំបន់ស្នូល** កំណត់យកតួភ្នំទាំងមូល

តំបន់នេះជាគោលដៅថែរក្សាបេតិកភ័ណ្ឌវប្បធម៌ និង ធម្មជាតិ តាមរយៈការចាត់ចែងវិធានការ ដើម្បីជំរុញការអភិវឌ្ឍឱ្យមានចិរភាព និង មានការវាយតំលៃហេតុប៉ះពាល់លើបរិស្ថាន ។

ប្លង់កំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ មានក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣
## ការគ្រប់គ្រង ថែទាំ និង ការពារ

**មាត្រា ៥.-**

ការអភិរក្សតំបន់នីមួយៗ សុទ្ធតែត្រូវបានគ្រប់គ្រង ថែទាំ និង ការពារ ស្របតាមទិសដៅចំណាត់ថ្នាក់តំបន់ ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ និង កំរិតនៃសារៈសំខាន់ដោយឡែកៗ ខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ធម្មជាតិ គោរពសិទ្ធិជាម្ចាស់របស់ប្រជា ពលរដ្ឋរស់នៅក្នុងតំបន់ទាំងមូល ខាងជីវភាពរស់នៅ និង លើកស្ទួយរមណីយដ្ឋានការពារឱ្យមានតំលៃកាន់តែខ្ពស់ឡើង ។

**មាត្រា ៦.-**

ត្រូវអនុវត្តនូវនយោបាយរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដើម្បីធានាការគ្រប់គ្រង ថែទាំ និងការពារ ដោយកំណត់ភាពម្ចាស់ការ ទទួលខុសត្រូវរបស់បណ្តាស្ថាប័នមានសមត្ថកិច្ច ដែលមានក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ទទួលអនុវត្តផ្ទាល់ ផ្អែកលើមាត្រា៥ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ។

បែបបទ និង នីតិវិធី នៃការគ្រប់គ្រង ថែទាំ និង ការពាររមណីយដ្ឋានការពារប្រាសាទព្រះវិហារ ក្នុងបណ្តាមាត្រាខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧.-**

បរិវេណ និង រាល់សកម្មភាពរបស់តំបន់និមួយៗ នៃរមណីយដ្ឋានការពារប្រាសាទព្រះវិហារ អាចពិនិត្យឡើងវិញហើយកែប្រែបាន ដោយផ្អែកលើរាល់លទ្ធផលនៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងស្ថានភាពជាក់ស្តែង ដើម្បីធានាដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រកបដោយនិរន្តរភាពដូចមានចែងក្នុងមាត្រា ៤ ។

ការកែប្រែតំបន់ និង រាល់សកម្មភាពពាក់ព័ន្ធនឹងរមណីយដ្ឋានប្រាសាទព្រះវិហារ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល ។


104° 38'
104° 40'
104° 42'
14° 22'
14° 24'
Preas Vihear
Kokir
1500m
A
B
C
D
E
T
8
219
1 14°23'19'' 104°40'54''
2 14 23 27 104 40 46
3 14 23 37 104 40 35
4 14 23 30 104 41 14
5 14 23 42 104 41 21
6 14 23 59 104 41 31
7 14 25 15 104 41 04
8 14 23 48 104 40 37
9 14 23 53 104 40 43
A 14 24 22 104 42 33
B 14 22 32 104 42 33
C 14 22 47 104 39 48
D 14 23 18 104 40 07
T 14 23 26 104 41 59
E 14 23 39 104 41 02
ប្រភពផែនទី :
ខ្នាត ១: ២០០០០០
GPS ឆ្នាំ២០០២
SPOT
1:50000
N
S
W
E

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មិនា ឆ្នាំ ២០០៣

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

៣៖ រកត.០៣០៣.១២៣ **នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ៩៥ ច ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ ចាន់**